ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Feb-2013, 16:00
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (២០)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (20)

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Judge Florence Ndepele Mwachande MUMBA
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# ដីកាបង្គាប់ឲ្យដាក់សំណៅជាសាធារណៈនៃបណ្តឹងសាទុក្ខរបស់នួន ជា ឯកសារលេខ (E189/3/1/1) ដោយមានការកោសលុប

---

**សហព្រះរាជអាជ្ញា**
ជា លាង

**ជនជាប់ចោទ**
នួន ជា

Andrew CAYLEY

| **<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>** | **<u>សហមេធាវីជនជាប់ចោទ នួន ជា</u>** |
| --- | --- |
| ពេជ អង្គ | សុន អរុណ |
| Elisabeth SIMONNEAU FORT | Victor KOPPE |

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“អ.វ.ត.ក”) ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” និង “អ.វ.ត.ក”) បានទទួល “បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥” ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា (“មេធាវីការពារក្តី”) នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ (“បណ្តឹងសាទុក្ខ”)[1]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខនេះ*ក្នុងនោះ* ដោយលើកទឡ្ហីករណ៍ថា មេធាវីការពារក្តីបានរំលោភលើកាតព្វកិច្ចវិជ្ជាជីវៈ និងក្រមសីលធម៌របស់ខ្លួនចំពោះ អ.វ.ត.ក នៅក្នុងការបញ្ចេញព័ត៌មាន សម្ងាត់ទៅក្រៅ[2]។ មេធាវីការពារក្តីបានជំទាស់តវ៉ាទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទិននឹងបញ្ហានេះ *ក្នុងនោះ* ដោយលើកទឡ្ហីករណ៍ ថា ព័ត៌មានសម្ងាត់នោះស្ថិត នៅក្នុងមជ្ឈដ្ឋានសាធារណៈរួចទៅហើយ[3]។

2. នៅពេលដាក់បណ្តឹងសាទុក្ខនេះ មេធាវីការពារក្តីបានស្នើឲ្យចាត់ចំណាត់ប្រភេទបណ្តឹងសាទុក្ខនេះជាប្រភេទឯកសារសាធារណៈ[4] ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចចាត់ប្រភេទបែបនេះ[5]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បណ្តឹងសាទុក្ខនេះដកស្រង់យ៉ាងច្រើនចេញពីអ្វីដែលមេធាវីការពារក្តីអះអាងថាជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង០០៣”) និងបញ្ចេញព័ត៌មានសម្ងាត់ដែលមាននៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ដូចជា ឈ្មោះរបស់ជនជាប់សង្ស័យនៅក្នុងសំណុំរឿង ០០៣ ជាដើម[6]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរនូវសេចក្តីបញ្ជាក់របស់មេធាវីការពារក្តីដែលថា

---

[1] ឯកសារ E189/3/1/1 សម្ងាត់។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឲ្យមានវិធានការជាបន្ទាន់ ដោយអនុលោមតាមវិធាន ៣៥” ឯកសារ E189/3/1/2 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៥-៥០។

[3] សារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខតាមវិធាន ៣៥ ឯកសារ E189/3/1/3 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣។

[4] បណ្តឹងសាទុក្ខ ទំព័រដំបូង។

[5] វិធាន ១០៦(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី៨ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ (“វិធានផ្ទៃក្នុង”) ចែងថា បណ្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខភ្លាមៗ ត្រូវដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។

[6] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨-៤៣។

"ទោះបីជា [ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង ០០៣] ជាឯកសារសម្ងាត់ក៏ដោយ ក៏សាធារណជនអាចរកមើលបានដែរ។ មេធាវីការពារក្ដីបានចូលមើលឯកសារនេះនៅគេហទំព័រ [...] នាពេលថ្មីៗនេះនៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១២ [...]។ មេធាវីការពារក្ដីសូមដាក់បញ្ចូលឯកសារនេះទៅក្នុងបណ្ដឹងសាទុក្ខនេះ ដោយពិចារណាថា ដោយសារវាជាប្រយោជន៍ផ្ទាល់របស់ នួន ជា ហេតុនេះយើងខ្ញុំសូមប្រើព័ត៌មាននៅក្នុងឯកសារនេះ ("សេចក្ដីបញ្ជាក់")[7]។

3. បន្ថែមទៅនឹងបណ្ដឹងសាទុក្ខនេះ មេធាវីការពារក្ដីបានដាក់បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ រួមជាមួយនឹងឯកសារភ្ជាប់ចំនួនបួន[8] និងបានស្នើឲ្យចាត់ចំណាត់ប្រភេទឯកសារទាំងនេះ ជាប្រភេទឯកសារសាធារណៈ[9] ជាចំណាត់ប្រភេទដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចបែបនេះដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់បង្ហាញ អាសយដ្ឋានគេហទំព័រ ដែលមេធាវីការពារក្ដីអះអាងថា អាចឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង ០០៣[10]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា នៅពេលដាក់ឯកសារនោះ ឯកសារភ្ជាប់ ២ ត្រូវបានដាក់ចំណងជើងថា ""'Julia Wallace: 'From Phnom Penh With Love', *International*

[7] បណ្ដឹងសាទុក្ខ ជើងទំព័រ ៨២ (សេចក្ដីបញ្ជាក់ ច្បាប់ដើម)។

[8] បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ឯកសារ E189/3/1/1.1 សម្ងាត់ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ("បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់") ទំព័រដំបូង។ បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយ អនុលោមតាមវិធាន ៣៥ ឯកសារភ្ជាប់១ ឯកសារ E189/3/1/1.1.1 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ("ឯកសារភ្ជាប់១") ។ បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយ អនុលោមតាមវិធាន ៣៥ ឯកសារភ្ជាប់២ ឯកសារ E189/3/1/1.1.2 សម្ងាត់បំផុត ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ("ឯកសារភ្ជាប់២") ។ បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយ អនុលោមតាមវិធាន ៣៥ ឯកសារភ្ជាប់៣ ឯកសារ E189/3/1/1.1.3 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ("ឯកសារភ្ជាប់៣")។ បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយ អនុលោមតាមវិធាន ៣៥ ឯកសារភ្ជាប់៤ ឯកសារ E189/1/1/1.1.4 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ("ឯកសារភ្ជាប់៤")។

[9] បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ទំព័រដំបូង។

[10] បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ កថាខណ្ឌ ៣០។

*Justice Tribune*, No. 148, 28 March 2012"[11] ទោះបីជាខ្លឹមសារពិតប្រាកដរបស់ឯកសារនេះគឺជាអ្វីដែលទំនងជាឯកសារថតចម្លងរបស់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង ០០៣ ក៏ដោយ។

4. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ឯកសារណាមួយដែលត្រូវបានស្នើសុំដាក់នោះ ត្រូវមានសំណើចំណាត់ប្រភេទឯកសារនោះ ដោយអនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ ហើយភាគីដែលដាក់ឯកសារត្រូវតែធានាថា ឯកសារដែលពួកគាត់ស្នើសុំឲ្យដាក់ចំណាត់ប្រភេទជាឯកសារសាធារណៈ មិនមានព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុតនោះទេ"[12]។ ការដែលឯកសារមួយដែលត្រូវបាន អ.វ.ត.ក ចាត់ប្រភេទថាជាឯកសារសម្ងាត់ អាចត្រូវបានលេចធ្លាយ ឬក៏អាចត្រូវបានដាក់ដោយខុសច្បាប់ទៅក្នុងមជ្ឈដ្ឋានសាធារណៈ មិនបានផ្តល់សិទ្ធិឲ្យមេធាវីការពារក្តីលាតត្រដាងឯកសារនោះ ឬព័ត៌មានដែលមាននៅក្នុងឯកសារនោះ ឬបន្តលាតត្រដាង និងផ្សព្វផ្សាយបន្ថែមទៀត ក្នុងរបៀបណាមួយដែលអាចធ្វើឲ្យប៉ះពាល់ដល់ចំណាត់ប្រភេទឯកសារដែលត្រូវបានកំណត់ដោយតុលាការរួចហើយនោះទេ"[13]។

5. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ប្រសិនបើមានការបង្ហាញឲ្យឃើញហួសពីវិមតិសង្ស័យ ការលាតត្រដាងឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយ គឺជាបទល្មើសមួយ អនុលោមតាមវិធាន ៣៥(១)(ក) នៃវិធានផ្ទៃក្នុង ដែលអាចនាំឲ្យមានការដាក់ទណ្ឌកម្មស្របតាមច្បាប់កម្ពុជា ព្រមទាំងអាចចាត់ទុកជាកំហុសវិជ្ជាជីវៈរបស់មេធាវី[14]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល មានក្តីបារម្ភដោយសារការគាំទ្រដោយឥតលាក់លៀមរបស់មេធាវីការពារក្តីចំពោះការរំលោភលើដីកាបង្គាប់របស់ អ.វ.ត.ក ជា

[11] សូមមើល បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ កថាខណ្ឌ ៣៣។

[12] មាត្រា ៣.១៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក វិសោធនកម្មលើកទី៨ ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ") *ដែលយោង*សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង វិសោធនកម្មលើកទី១ ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ")។

[13] ប្រៀបធៀប បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨-៤២ ដែលដកស្រង់ចេញពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ សម្ងាត់។

[14] សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារ E116/1/7 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ") កថាខណ្ឌ ៣៦ *ដែលដកស្រង់*វិធាន ៣៥(២), ៣៥(៤), ៣៥(៥) និង ៣៨ នៃវិធានផ្ទៃក្នុង។

ពិសេស ដោយពិចារណាទៅលើការព្រមានដដែលៗកាលពីលើកមុនៗទៅលើកំហុសឆ្គងស្រដៀងគ្នានេះ[15]។ នៅក្នុងករណីនេះ ទោះបីជាមេធាវីការពារក្តីអាចចាត់ទុកថាជា "ផលប្រយោជន៍ផ្ទាល់"[16] របស់ នួន ជា ក្នុងការប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងអ្វីដែលមេធាវីការពារក្តីជឿថាជា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង ០០៣ យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានផលប្រយោជន៍សម្រាប់ នួន ជា ឡើយ នៅក្នុងការបន្តលាតត្រដាងដោយមិនត្រឹមត្រូវរបស់មេធាវីការពារក្តីនោះ។ ជាចំណាត់ការដ៏សមរម្យនោះ មេធាវីការពារក្តីគួរដាក់បណ្តឹងសាទុក្ខ បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ និងឯកសារភ្ជាប់ ២ ដោយសម្ងាត់ រួមជាមួយនឹងសំណៅកោសលុបនៃបណ្តឹងសាទុក្ខជាសាធារណៈនៅពេលសមស្រប[17]។ ការអនុវត្តបែបនេះនឹងធានានូវផលប្រយោជន៍របស់ នួន ជា ក្នុងការប្រើប្រាស់ព័ត៌មាន ដោយមិនរំលោភទៅលើផលប្រយោជន៍ផ្សេងៗដទៃទៀត ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចក្នុងការចាត់ចំណាត់ប្រភេទឯកសារជាឯកសារសម្ងាត់។

6. អនុលោមតាមមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើចំណាត់ថ្នាក់ឯកសារជាថ្មីលើបណ្តឹងសាទុក្ខ និងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ឲ្យទៅជាឯកសារសម្ងាត់ និងឯកសារភ្ជាប់ ២ ឲ្យទៅជាឯកសារសម្ងាត់បំផុត[18]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅពេលដែលអង្គជំនុំជម្រះធ្វើចំណាត់ថ្នាក់ឯកសារជាថ្មីដោយប្តូរពីឯកសារសាធារណៈឲ្យទៅជា

---

[15] សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ៣៧។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩។ សេចក្តីព្រមានចំពោះការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត ឯកសារ D314/1/11 ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១០។

[16] សេចក្តីបញ្ជាក់។

[17] ចំណាត់ការស្រដៀងគ្នាមួយត្រូវបានស្នើឡើងជាយោបល់ជូនមេធាវីការពារក្តីរួចហើយនៅក្នុងកាលៈទេសៈស្រដៀងគ្នានេះ។ សូមមើល សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ៣៦។

[18] ទោះបីជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង ០០៣ ត្រូវបានចាត់ចំណាត់ប្រភេទជាឯកសារសម្ងាត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាជាការសមស្របបំផុតនៅក្នុងករណីបច្ចុប្បន្ននេះក្នុងការធ្វើចំណាត់ប្រភេទជាថ្មីលើឯកសារភ្ជាប់ ២ ជាប្រភេទឯកសារសម្ងាត់បំផុត ដោយពិចារណាថា អង្គជំនុំជម្រះមិនបានទទួលសំណុំរឿង ០០៣ ដែលស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតនៅឡើយ។

ឯកសារសម្ងាត់វិញ ភាគីដែលពាក់ព័ន្ធគួរតែត្រូវបានណែនាំឲ្យដាក់សំណៅកោសលុបជាសាធារណៈ ដើម្បីឆ្លើយតបនឹងតម្រូវការទូទៅក្នុងការធានាអំពីតម្លាភាពនៃកិច្ចដំណើរការនីតិវិធី[19]។

7. ផ្អែកតាមសំអាងហេតុខាងលើនេះ **អង្គជំនុំជម្រះតុលាការកំពូល** ដោយអនុលោមតាមវិធាន ៣៥(២)(ក) និងវិធាន ៣៥(១)(ក) នៃវិធានផ្ទៃក្នុង និងមាត្រា ៩.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ៖

**ណែនាំ** ឲ្យមេធាវីការពារក្តី ដាក់សំណៅកោសលុបសម្រាប់សាធារណៈនៃបណ្តឹងសាទុក្ខ និងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ មិនឲ្យហួសពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឡើយ។

**ណែនាំ** មេធាវីការពារក្តីធានាថា ការកែប្រែចំពោះសំណៅសម្ងាត់នៃបណ្តឹងសាទុក្ខ និងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ត្រូវកំហិតត្រឹមតែការកោសលុបដែលចាំបាច់ទៅលើព័ត៌មានសម្ងាត់ប៉ុណ្ណោះ ដូចជាសម្រង់ និង/ឬខ្លឹមសារពិពណ៌នារបស់សំណៅនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង ០០៣ ដែលត្រូវបានចោទប្រកាន់ និង ឈ្មោះរបស់ជនជាប់សង្ស័យក្នុងសំណុំរឿង ០០៣ ដែលមានបញ្ចាក់នៅក្នុងកថាខណ្ឌ ៣៨ ដល់ ៤៣ នៃ បណ្តឹងសាទុក្ខ និងអាសយដ្ឋានគេហទំព័រ ដែលមាននៅក្នុងកថាខណ្ឌ ៣០ នៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ និងមិនត្រូវបន្ថែម ឬលុបព័ត៌មាន ឬកែប្រែត្រង់ចំណុចណាផ្សេងទៀតនោះទេ។

**ណែនាំ** មេធាវីការពារក្តី ឲ្យដាក់សញ្ញាសម្គាល់ឲ្យបានច្បាស់លើផ្នែកដែលបានកោសលុបសម្រាប់សាធារណៈ នៃអត្ថបទបណ្តឹងសាទុក្ខ និងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ឬដាក់ឧបសម្ព័ន្ធសម្ងាត់ទៅនឹងបណ្តឹងសាទុក្ខ ដោយបញ្ជាក់អំពីចំណុចដែលខ្លួនបានកោសលុបទាំងអស់។

---

[19] ដីកាបង្គាប់ឲ្យដាក់ឯកសារលេខ (E238/9/2/1) នៃបណ្តឹងសាទុក្ខរបស់ អៀង សារី ជាសាធារណៈដោយមានការកោសលុប ឯកសារ E238/9/2/3 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥ *ដែលយោងវិ*ធាន ២៩(៤)(ង), ៥៥, ៥៦(២)(ក), ៦៦(១), ៧៨, ៧៩(៦), ១០២(១), ១០៩(១) និង ១១៣(៤) នៃវិធានផ្ទៃក្នុង។ មាត្រា ១.២, ៣.១៣, ៣.១៤, ៤-៦, ៩.២ និង ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។

**រំឭក** មេធាវីការពារក្តីឲ្យយកចិត្តទុកដាក់ឲ្យកាន់តែខ្លាំងក្នុងការស្នើសុំធ្វើចំណាត់ប្រភេទឯកសារសមស្រប ដោយយោងតាមសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទនេះ ហើយធានាថា ការដាក់ឯកសារដែលខ្លួនស្នើសុំធ្វើចំណាត់ប្រភេទជាសាធារណៈនោះ មិនមានព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ឡើយ។ និង

**ណែនាំ** អង្គជំនុំជម្រះសាលាដំបូងឲ្យដាក់ចំណាត់ប្រភេទគ្រប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខភ្លាមៗទាំងអស់នាពេលអនាគត ជាឯកសារ"សម្ងាត់បណ្តោះអាសន្ន"ដើម្បីអាចឲ្យអង្គជំនុំជម្រះតុលាការកំពូលកំណត់ និងសម្រេចពីចំណាត់ប្រភេទសមស្របនៃឯកសារទាំងនោះ។

**ភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

**គង់ ស្រ៊ីម**